**អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**
**អគ្គនាយកដ្ឋានស្រាវជ្រាវ**
**នាយកដ្ឋានស្រាវជ្រាវថវិកា**

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

**មាតិកា៖**

- ធនាគារជាតិនៃកម្ពុជា ដាក់ចេញវិធានការដោះស្រាយបំណុល ដំណាក់កាលទីបី
- ពាណិជ្ជកម្មកម្ពុជា-ជប៉ុន កើនឡើង៦,៦% នៅក្នុងត្រីមាសទី១ ឆ្នាំ២០២១
- ការប្រៀបធៀបការប្រមូលចំណូលរដ្ឋ ក្នុងត្រីមាសទី១ ឆ្នាំ២០២១
- ការប្រៀបធៀបការប្រមូលចំណូលរដ្ឋ ក្នុងខែមីនា ឆ្នាំ២០២១
- ឧស្សាហកម្ម អាចវិលត្រឡប់ទៅប្រទេសចិនវិញ ដោយសារករណីឆ្លងនៃជំងឺកូវីដ-១៩កើនឡើងយ៉ាងខ្លាំង នៅប្រទេសឥណ្ឌា និងប្រទេសវៀតណាម
- ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម (NESDC) ប្រទេសថៃ បានធ្វើការព្រមានពីការកើនឡើងនៃការបាត់បង់ការងារ
- ថវិកាចរន្តរបស់ប្រទេសសិង្ហបុរី សម្រាប់ឆ្នាំ២០២១
- ទីផ្សារអចលនទ្រព្យពិភពលោក ត្រៀមនឹងកើនឡើងនៅឆ្នាំនេះ
- ការកើនឡើងខ្ពស់នៃកម្រិតបំណុលនៅប្រទេសសេដ្ឋកិច្ចកំពុងរីកចម្រើន អាចនឹងធ្វើឱ្យការស្តារឡើងវិញនៃសេដ្ឋកិច្ចពីវិបត្តិជំងឺកូវីដ-១៩ មានភាពយឺតយ៉ាវ និងពង្រីកគម្លាតជាមួយប្រទេសសេដ្ឋកិច្ចអភិវឌ្ឍន៍

ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គីម សុចិត្រា អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមរៈ អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ធនាគារជាតិនៃកម្ពុជា ដាក់ចេញវិធានការដោះស្រាយបំណុលដំណាក់កាលទីបី



*ប្រភព៖ Phnom Penh Post ២០២១ រូបភាព៖ NBC*

ធនាគារជាតិនៃកម្ពុជា(NBC) បានដាក់ចេញនូវវិធានការដោះស្រាយបំណុលដំណាក់កាលទី៣ ក្នុងគោលបំណងផ្តល់ឱ្យស្ថាប័នហិរញ្ញវត្ថុ(FI) នូវការជំរុញបន្ថែមដែលអាចឱ្យពួកគេដាក់ប្រាក់កម្ចីបន្ថែមទៀត ដើម្បីជំរុញសកម្មភាពសេដ្ឋកិច្ច ខណៈដែលកម្ពុជាកំពុងខិតខំដើម្បីធ្វើឱ្យប្រសើរឡើងវិញ ដោយសារការផ្ទុះរីករាលដាលក្នុងសហគមន៍ នៃមេរោគកូវីដ-១៩ នាព្រឹត្តិការណ៍២០ កុម្ភៈ។

ធនាគារកណ្តាល នឹងរក្សាអនុបាតតម្រូវការបំរុង (RRR) នៅត្រឹម៧% រហូតដល់មានការជូនដំណឹងបន្ថែម រួមទាំងបន្តរៀបចំរចនាសម្ព័ន្ធប្រាក់កម្ចីរបស់ខ្លួន រហូតដល់ថ្ងៃទី ៣១ ខែធ្នូ។ RRRs គឺជាបទប្បញ្ញត្តិរបស់ធនាគារកណ្តាល ដែលកំណត់ចំនួនទឹកប្រាក់អប្បបរមាដែល FIs ត្រូវរក្សាទុកជាទុនបំរុង។ RRR ក្នុងរូបិយប័ណ្ណបរទេសមានចំនួន១២,៥% និងក្នុងស្រុកមានចំនួន ៨% រហូតទាល់តែធនាគារជាតិនៃកម្ពុជាកាត់បន្ថយទាំងពីរ មកត្រឹម៧% កាលពីខែមីនាឆ្នាំមុន។

ជាមួយគ្នានេះ អតិថិជននៅក្នុងតំបន់ដែលជាប់ទាក់ទងដោយសារតែការរឹតបន្តឹងនៃជំងឺកូវីដ-១៩ អាចនឹងរៀបចំរចនាសម្ព័ន្ធប្រាក់កម្ចីរបស់ពួកគេឱ្យបានច្រើនដងតាមតម្រូវការ ឬដកវិញនូវការកំណត់ត្រឹម៣ដង។ ធនាគារជាតិ បានលើកទឹកចិត្តស្ថាប័នហិរញ្ញវត្ថុ ឱ្យពិចារណាលើការកាត់បន្ថយ ឬលើកលែងថ្លៃសេវា ឬការដាក់ពិន័យលើសេណារីយ៉ូករណីនីមួយៗ។

ដោយឡែក យោងតាមរបាយការណ៍ប្រចាំឆ្នាំ ២០២០ របស់ NBC ទ្រព្យសកម្មសរុបនៅក្នុងធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា បានកើនឡើងដល់ ៥៩,៤ប៊ីលានដុល្លារនៅចុងឆ្នាំ២០២០ គឺកើនឡើង ១៥,៧% ធៀបនឹងចុងឆ្នាំ២០១៩។ រីឯប្រាក់កម្ចីសរុបនៅក្នុងធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បានកើនឡើង ១៤,៨% រហូតដល់៣៧,៣ប៊ីលានដុល្លារនៅចុងឆ្នាំ២០២០ ខណៈពេលដែលប្រាក់បញ្ញើបានកើនឡើង ១៥,៤% រហូតដល់ ៣៣,៨ពាន់លានដុល្លារ។

*ដោយ វុត្ថា វង្សវឌ្ឍនៈ*

*ប្រភព៖ Phnom Penh Post ចេញផ្សាយថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២១*

## ពាណិជ្ជកម្មកម្ពុជា-ជប៉ុន កើនឡើង៦,៦% នៅក្នុងត្រីមាសទី១ ឆ្នាំ២០២១



*ប្រភព៖ Khmer Times ២០២១ រូបភាព៖ pixabay/ ChorkNiarin - DavidRockDesign*

ពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា និងជប៉ុន នៅត្រីមាសទី១ ឆ្នាំ ២០២១ បានកើនឡើង ៦,៦% បើប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២០ ដោយបានកើនឡើងដល់ចំនួន ៦៣២លានដុល្លារ។ យោងតាមទិន្នន័យពីអង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុន(JETRO) បានឱ្យដឹងថា តម្លៃនៃការនាំចូលពីប្រទេសជប៉ុន មានចំនួនច្រើនជាងការនាំចេញរបស់កម្ពុជាទៅជប៉ុន។ ចាប់ពីខែមករាដល់ខែមីនា ប្រទេសកម្ពុជាបាននាំចូលផលិតផលពីប្រទេសជប៉ុន មានតម្លៃ ៤៨៩លានដុល្លារ កើនឡើង ៣% លើសតួលេខត្រីមាសទី១ឆ្នាំ២០២០។ រីឯការនាំចេញរបស់កម្ពុជាទៅប្រទេសជប៉ុនក្នុងត្រីមាសទី១ កើនដល់ ១៤៣លានដុល្លារដែលកើនឡើង ២៨.៥% លើសតួលេខត្រីមាសទី១ កាលពីឆ្នាំ ២០២០ ។

យោងតាមក្រសួងពាណិជ្ជកម្ម បានឱ្យដឹងថាការនាំចេញដ៏សំខាន់របស់ប្រទេសកម្ពុជាទៅកាន់ប្រទេសជប៉ុន គឺសម្លៀកបំពាក់ កាបូប ស្បែកជើង គ្រឿងសង្ហារឹម គ្រឿងសំអាង ក្រដាស សម្ភារៈការិយាល័យ និងទំនិញស្បែក ខណៈដែលការនាំចេញរបស់ជប៉ុនមកកម្ពុជារួមមាន គ្រឿងម៉ាស៊ីនរថយន្ត គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារឹម ក្រណាត់ និងប្លាស្ទិក។ គួររំលឹកដែរថា នៅឆ្នាំ២០២០ ពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសទាំងពីរ មានតម្លៃ ២,០៩៩ប៊ីលានដុល្លារ ពោលគឺធ្លាក់ចុះ ៨% បើប្រៀបធៀបនឹងឆ្នាំ ២០១៩ ។

ជាមួយគ្នានេះ ក្រសួងពាណិជ្ជកម្មធ្លាប់បានលើកឡើងថា បន្ទាប់ពីប្រទេសចិន និងកូរ៉េខាងត្បូង ប្រទេសកម្ពុជាកំពុងសម្លឹងមើលប្រទេសជប៉ុន ឥណ្ឌា និងប្រទេសមួយចំនួនទៀត សម្រាប់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ដែលមានគោលបំណងពង្រីកទីផ្សារនៃផលិតផលកម្ពុជា។

*ដោយ វត្ថា វង្សវឌ្ឍនៈ*

*ប្រភព៖ Khmer Times ចេញផ្សាយថ្ងៃទី២៥ ខែឧសភាឆ្នាំ២០២១*

### តារាងប្រចាំសប្តាហ៍ ៖

### តារាងទី១៖ ការប្រៀបធៀបការប្រមូលចំណូលរដ្ឋក្នុងត្រីមាសទី១ ឆ្នាំ២០២១

| ចំណូល(ប៊ីលានរៀល) | អនុវត្តន៍ ត្រីមាសទី១ | | ច្បាប់ | | ធៀបនឹងច្បាប់ ត្រីមាសទី១ | | កំណើន(%) ត្រីមាសទី១ |
|---|---|---|---|---|---|---|---|
| | 2020 | 2021 | 2020 | 2021 | 2020 | 2021 | (2020-21) |
| **ចំណូលក្នុងស្រុកសរុបថ្នាក់ជាតិ** | **5,540** | **5,127** | **24,093** | **19,927** | **22.99%** | **25.73%** | **-7.45%** |
| **១.ចំណូលចរន្ត** | **5,519** | **5,106** | **23,899** | **19,706** | **23.09%** | **25.91%** | **-7.49%** |
| ក.ចំណូលសារពើពន្ធ | 4,697 | 4,507 | 21,091 | 17,520 | 22.27% | 25.72% | **-4.05%** |
| ខ.ចំណូលមិនមែនសារពើពន្ធ | 822 | 599 | 2,808 | 2,186 | 29.29% | 27.42% | **-27.12%** |
| **២.ចំណូលមូលធន** | **20** | **21** | **193** | **221** | **10.44%** | **9.27%** | **1.54%** |

*ប្រភព៖ ការអនុវត្តថវិការដ្ឋ ខែធ្នូ ឆ្នាំ២០២០ និងការអនុវត្តថវិការដ្ឋ ខែមីនា ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១*

**តារាងទី១៖** យោងតាមទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបង្ហាញថា៖ ការអនុវត្តលើការប្រមូលចំណូលក្នុងស្រុកសរុបក្នុងត្រីមាសទី១ ឆ្នាំ២០២១ មានការធ្លាក់ចុះ ៧,៤៥% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០២០។

ជាក់ស្តែង ក្នុងត្រីមាសទី១ ចំណូលក្នុងប្រទេសសរុបថ្នាក់ជាតិអនុវត្តបាន ២៥,៧៥% នៃច្បាប់ហិរញ្ញវត្ថុ ឬស្មើនឹង ៥ ១២៧ ប៊ីលានរៀល។ ក្នុងនោះដែរ ចំណូលសារពើពន្ធមានចំនួនប្រមាណ ៤ ៥០៧ ប៊ីលានរៀល ឬធ្លាក់ចុះ ៤%ធៀបនឹងត្រីមាសទី១កាលពីឆ្នាំមុន ដែលការធ្លាក់ចុះនេះ អាចបណ្តាលមកពីកត្តាមួយចំនួន ដូចជាការធ្លាក់ចុះនូវប្រភពចំណូលពន្ធប្រយោល និងពាណិជ្ជកម្មក្រៅប្រទេស។ ចំណែកឯ ចំណូលមិនមែនសារពើពន្ធមានចំនួន ៥៩៩ ប៊ីលានរៀន គឺធ្លាក់ចុះ ២៧% ដែលការថយនេះ បណ្តាលមកពីការធ្លាក់ចុះនូវប្រភពចំណូលដែលបានមកពីការប្រមូលផលទុននៃទ្រព្យសម្បត្តិរដ្ឋ ផលទុនពីសហគ្រាសសាធារណៈ ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិនិងសេវាកម្ម និងកម្រៃប្រតិបត្តិការផ្សេងៗ។ រីឯ ចំណូលមូលធនមានចំនួនប្រហែល ២១ប៊ីលានរៀល ឬ កើន១,៥៤% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០២០។

សរុបជារួម ការធ្លាក់ចុះនូវចំណូលថវិកាជាតិនេះ ត្រូវបានបង្ហាញថា ដោយសារការថមថយសកម្មភាពសេដ្ឋកិច្ចក្នុងបរិការណ៍ ការរីករាលដាលនៃជំងឺកូវីដ-១៩ និងការអនុវត្តវិធានការអន្តរាគមន៍របស់រាជរដ្ឋាភិបាល ក៏ដូចជាការលើកលែងការបង់ពន្ធប្រចាំខែគ្រប់ប្រភេទ ជាពិសេសលើវិស័យទេសចរណ៍ អាកាសចរស៊ីវិល និងនេសាទ៕

*ដោយ ឈន ហាំ*

## តារាងទី២៖ ការប្រៀបធៀបការប្រមូលចំណូលរដ្ឋ ក្នុងខែមីនា ឆ្នាំ២០២១

| ចំណូល(ប៊ីលានរៀល) | អនុវត្តន៍ | | ច្បាប់ | | ធៀបនឹងច្បាប់ | | កំណើន(%) |
|---|---|---|---|---|---|---|---|
| | Mar-20 | Mar-21 | 2020 | 2021 | Mar-20 | Mar-21 | Mar(2020-21) |
| **ចំណូលក្នុងស្រុកសរុបថ្នាក់ជាតិ** | **1,971** | **1,931** | **24,093** | **19,927** | **8.18%** | **9.69%** | **-2.00%** |
| **១.ចំណូលចរន្ត** | **1,954** | **1,914** | **23,899** | **19,706** | **8.18%** | **9.71%** | **-2.04%** |
| ក.ចំណូលសារពើពន្ធ | 1,752 | 1,818 | 21,091 | 17,520 | 8.31% | 10.38% | **3.79%** |
| ខ.ចំណូលមិនមែនសារពើពន្ធ | 202 | 96 | 2,808 | 2,186 | 7.19% | 4.39% | **-52.53%** |
| **២.ចំណូលមូលធន** | **17** | **17** | **193** | **221** | **8.70%** | **7.75%** | **1.90%** |

*ប្រភព៖ ការអនុវត្តថវិការដ្ឋ ខែធ្នូ ឆ្នាំ២០២០ និងការអនុវត្តថវិការដ្ឋ ខែមីនា ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១*

**តារាងទី២៖** យោងតាមទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបង្ហាញថា៖ ការអនុវត្តលើការប្រមូលចំណូលក្នុងស្រុកសរុបក្នុងខែមីនា ឆ្នាំ២០២១ មានការធ្លាក់ចុះ ២% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០២០។

ជាក់ស្តែង ក្នុងខែមីនា ឆ្នាំ២០២១នេះ ចំណូលក្នុងប្រទេសសរុបថ្នាក់ជាតិអនុវត្តបានជិត ១០% នៃច្បាប់ហិរញ្ញវត្ថុ ឬស្មើនឹង ១ ៩៣១ ប៊ីលានរៀល។ ក្នុងនោះដែរ ចំណូលសារពើពន្ធមានចំនួន ១ ៨១៨ ប៊ីលានរៀល គឺធ្លាក់ចុះជិត ៤% ដែលការធ្លាក់ចុះនេះ អាចបណ្តាលមកពីការធ្លាក់ចុះនូវប្រភពចំណូលពន្ធប្រយោល។ ចំណែកឯ ចំណូលមិនមែនសារពើពន្ធមានចំនួនប្រមាណ ៩៦ ប៊ីលានរៀល គឺធ្លាក់ចុះខ្លាំងរហូតដល់ជិត ៥៣% ដែលការធ្លាក់ចុះនេះ បណ្តាលមកពីការធ្លាក់ចុះនូវចំណូល ដែលបានមកពីការប្រមូលផលទុននៃទ្រព្យសម្បត្តិរដ្ឋ ផលទុន

ពីសហគ្រាសសាធារណៈ ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិនិងសេវាកម្ម និងកម្រៃប្រតិបត្តិការផ្សេងៗ។ រីឯចំណូលមូលធនមានចំនួន ១៧ ប៊ីលានរៀល ឬ កើនជិត ២% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០២០។

ជារួម ការធ្លាក់ចុះនូវចំណូលថវិកាជាតិនេះ ត្រូវបានបង្ហាញថា ដោយសារសកម្មភាពសេដ្ឋកិច្ចថយចុះ ក្នុងបរិការណ៍ការរីករាលដាលនៃជំងឺកូវីដ-១៩ និងការអនុវត្តវិធានការអន្តរាគមន៍របស់រាជរដ្ឋាភិបាល ក៏ដូចជាការលើកលែងការបង់ពន្ធប្រចាំខែគ្រប់ប្រភេទ ជាពិសេសលើវិស័យទេសចរណ៍ អាកាសចរស៊ីវិល និងនេសាទ ជាដើម៕ *ដោយ ឈន ហាំ*

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ឧស្សាហកម្មអាចវិលត្រឡប់ទៅប្រទេសចិនវិញ ដោយសារករណីឆ្លងនៃជំងឺកូវីដ-១៩កើនឡើងយ៉ាងខ្លាំងនៅប្រទេសឥណ្ឌា និងប្រទេសវៀតណាម



*ប្រភព៖CNBC, 2021 រូបភាព៖ Barcroft Media | Getty Images*

យោងតាមការលើកឡើងរបស់អ្នកសេដ្ឋកិច្ចម្នាក់បានអោយដឹងថា ការឆ្លងឡើងវិញនៃជំងឺកូវីដ-១៩ នៅតំបន់ខ្លះនៃទ្វីបអាស៊ីអាចនាំឱ្យមានការផ្លាស់ប្តូរសម្រាប់ប្រទេសចិន។ គួរបញ្ជាក់ផងដែរ សង្គ្រាមពាណិជ្ជកម្មសហរដ្ឋអាមេរិក-ចិន បានបណ្តាលឱ្យក្រុមហ៊ុនជាច្រើនបានផ្លាស់ប្តូរខ្សែសង្វាក់ផ្គត់ផ្គង់របស់ពួកគេ ចេញពីប្រទេសចិន ដែលក្នុងនោះរួមមានការផ្លាស់ប្តូរបណ្តាញផលិតកម្ម និងការចែកចាយផលិតផលនិងសេវាកម្ម ទើបធ្វើឱ្យបណ្តាប្រទេសដូចជាវៀតណាម និងឥណ្ឌា ទទួលបានអត្ថប្រយោជន៍នៅពេលក្រុមហ៊ុនផ្លាស់ប្តូរទៅបង្កើតទីតាំងនៅក្នុងប្រទេសទាំងពីរនេះ។

លោក Zhang Zhiwei ប្រធានសេដ្ឋវិទូនៅក្រុមហ៊ុន Pinpoint Asset Management បាននិយាយថា ស្របពេលនេះដែរ ប្រទេសឥណ្ឌា និងប្រទេសវៀតណាម មានការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ សារជាថ្មី អាចផ្តល់នូវឱកាសឡើងវិញសម្រាប់ប្រទេសចិន។

មុនពេលមានជំងឺរាតត្បាតឆ្លងសារជាថ្មី គេបានឃើញថារោងចក្រធំៗជាច្រើនបានចាកចេញពីប្រទេសចិនទៅរៀបចំរោងចក្រនៅវៀតណាម និងឥណ្ឌា ប៉ុន្តែដោយសារការកើនឡើងនូវករណីឆ្លងនៅក្នុងប្រទេសទាំងពីរ បានបង្ខំឱ្យរោងចក្រដែលគ្រប់គ្រងដោយក្រុមហ៊ុនតៃវ៉ាន់ Foxconn ដែលជាក្រុមហ៊ុនផ្គត់ផ្គង់ដ៏ធំរបស់ក្រុមហ៊ុន Apple ត្រូវបិទទ្វាររោងចក្រនៅឥណ្ឌា និងវៀតណាម។ ការណ៍នេះ អាចធ្វើឲ្យការផ្លាស់ប្តូរទីតាំងខ្សែសង្វាក់ផ្គត់ផ្គង់ ត្រូវបានផ្អាកមួយរយៈ ស្របពេលដែលការធ្វើដំណើរអន្តរជាតិត្រូវបានផ្អាក ដូច្នេះក្រុមហ៊ុនពហុជាតិមិនអាចបញ្ជូនបុគ្គលិករបស់ពួកគេទៅកាន់ប្រទេសឥណ្ឌា និងវៀតណាមដើម្បីបង្កើតរោងចក្រថ្មីបានទេ។

តាមរយៈការព្យាករណ៍របស់អ្នកសេដ្ឋកិច្ចបានឱ្យដឹងថាសេដ្ឋកិច្ចអាស៊ីខាងត្បូងអាចនឹងធ្លាក់ចុះនៅត្រីមាសនេះ។

នៅភាគខាងជើងខេត្ត Bac Giang ប្រទេសវៀតណាម បានបញ្ជាឱ្យឧទ្យានឧស្សាហកម្មចំនួន ៤ ក្នុងនោះមានអគាររោងចក្រផលិតចំនួន ៣ នៃ Foxconn របស់តៃវ៉ាន់ត្រូវបិទជាបណ្ដោះអាសន្ន ដោយសារតែការផ្ទុះឡើងនៃកូវីដ-១៩ ដែលស្ថានភាពនេះអាចផ្តល់ផលប្រយោជន៍ដល់ប្រទេសចិន។

ជាក់ស្តែង បច្ចុប្បន្នកំណើននៃការនាំចេញនៅក្នុងប្រទេសចិនមានអត្រាចន្លោះពី ២០% ទៅ ៤០% ក្នុងមួយខែ។ ប៉ុន្តែ ប្រសិនបើរោងចក្រនៅក្នុងប្រទេសឥណ្ឌា និងវៀតណាមអាចដំណើរការឆាប់ៗដូចដើមវិញការនាំចេញរបស់ប្រទេសចិន នឹងត្រូវបានរំពឹងថាធ្លាក់ចុះនៅឆមាសទី២ នៃឆ្នាំនេះ ដោយសារក្រុមហ៊ុនផ្លាស់ប្តូររោងចក្រផលិតរបស់ពួកគេទៅកាន់ប្រទេសទាំងពីរនោះវិញ។

ក្នុងករណី ដែលខ្សែសង្វាក់ផ្គត់ផ្គង់នៅក្នុងប្រទេសឥណ្ឌា និងវៀតណាម ត្រូវបានបន្តអាក់ខានរយៈពេលយូរ នោះកំណើននៃការនាំចេញរបស់ប្រទេសចិនគឺអាចបន្តកើនឡើង ដល់ ២០% ទៅ៣០%នៅឆ្នាំក្រោយ៕

*ដោយ សេន ចន្ទី*

*ប្រភព៖ CNBC.Com ចេញផ្សាយថ្ងៃទី២៤ខែឧសភា ឆ្នាំ២០២១*

## ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម (NESDC) ប្រទេសថៃ បានព្រមានពីការកើនឡើងនៃការបាត់បង់ការងារ



*ប្រភព៖bangkokpost 2021 រូបភាព៖ Apichart Jinakul*

យោងតាមការលើកឡើងរបស់អង្គភាពផែនការនៃរាជរដ្ឋាភិបាលប្រទេសថៃ ភាពគ្មានការងារធ្វើទំនងជានឹងកើនឡើងនៅឆ្នាំនេះ ដោយសារផលប៉ះពាល់ធ្ងន់ធ្ងរលកទី ៣ នៃ ជំងឺកូវីដ-១៩ ។ លោក Danucha Pichayanan អគ្គលេខាធិការនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គម (NESDC) បានមានប្រសាសន៍ថា លកនៃការរាតត្បាតលើកទី៣ ទំនងជាមានការអូសបន្លាយរយៈពេលយូរ និងរារាំងសេដ្ឋកិច្ចមិនឱ្យឈានដល់គោលដៅដោយសារតែសកម្មភាព សេដ្ឋកិច្ចមានការធ្លាក់ចុះ។ ទន្ទឹមនឹងនេះ កម្មករនៅក្នុងសហគ្រាសធុនតូចនិងមធ្យម (MSMEs) អាចជួបនូវការបាត់បង់ការងារច្រើនបំផុត ឬត្រូវទទួលយកការកាត់បន្ថយម៉ោងធ្វើការ ដោយសារអាជីវកម្មទាំងនេះរងផលប៉ះពាល់យ៉ាងខ្លាំងចាប់តាំងពីឆ្នាំមុន។ ផលិតផលក្នុងស្រុកសរុប (GDP) ដែលរួមចំណែកដោយសហគ្រាសធុនតូច និងមធ្យម បាន ធ្លាក់ចុះ ៩,១%។ ប្រសិនបើការផ្ទុះឡើង

នៃជំងឺកូវីដ១៩នេះ មិនត្រូវបានទប់ស្កាត់យ៉ាងឆាប់រហ័ស អាជីវកម្មទាំងនោះ នឹងមិនអាចបន្តប្រតិបត្តិការបានទេ ដែលបណ្តាលឱ្យមានការបញ្ឈប់និយោជិកជាអចិន្ត្រៃយ៍ និងពន្យារពេលការងើបឡើងវិញនៃសេដ្ឋកិច្ច។ រីឯ កម្មករនៅក្នុងឧស្សាហកម្មទេសចរណ៍ ក៏នឹងត្រូវបញ្ឈប់ពីការងារជាច្រើនផងដែរ។

មជ្ឈមណ្ឌលស្រាវជ្រាវទីផ្សារទេសចរណ៍ នៃ TAT បានព្យាករណ៍ថាវិស័យទេសចរណ៍ទំនងជានឹងវិលមករកភាពប្រក្រតីវិញនៅឆ្នាំ ២០២៦។ ផលប៉ះពាល់នៃជំងឺកូវីដ-១៩ នឹងពន្យារពេលដំណើរការធម្មតាឡើងវិញនៃវិស័យទេសចរណ៍ ហើយនឹងបង្កផលប៉ះពាល់ដល់បុគ្គលិកវិស័យទេសចរណ៍ជាង ៧លាននាក់។ បញ្ហាខាងលើនេះនឹងបណ្តាលឱ្យមានការងារមិនគ្រប់គ្រាន់សម្រាប់និស្សិតទើបបញ្ចប់ការសិក្សា។ ជាមួយគ្នានេះដែរ ស្របពេលដែលសេដ្ឋកិច្ចមានកំណើនយឺតជាងការរំពឹងទុក សហគ្រិនបានធ្វើការពន្យារពេលក្នុងការជួលបុគ្គលិកថ្មី ដែលនឹងប៉ះពាល់ដល់និស្សិតបញ្ចប់ការសិក្សាថ្មីចំនួន៤៩ម៉ឺននាក់។

គួរបញ្ជាក់ផងដែរ កម្មវិធីផ្តល់ប្រាក់កម្ចីសម្រាប់និស្សិតទើបបញ្ចប់ការសិក្សា និងកម្មករ ដែលមានរយៈពេល ១២ខែ ជិតដល់ពេលបញ្ចប់ហើយ ដែលបញ្ហានេះអាចប៉ះពាល់ដល់កម្មករជាង ១៤ម៉ឺននាក់។ ចំណែកគុណភាពជីវិតរបស់កម្មករក៏នឹងទទួលផលប៉ះពាល់ផងដែរ ដោយសារម៉ោងធ្វើការរបស់ពួកគេត្រូវបានកាត់បន្ថយក្នុងរយៈពេល ៦ ត្រីមាសជាប់ៗគ្នា។

ចាប់តាំងពីការផ្ទុះឡើងនៃជំងឺកូវីដ-១៩ នាឆ្នាំ ២០២០ កម្មករធ្វើការក្នុងប្រព័ន្ធដែលបានបញ្ឈប់ការងារជាច្រើន បានក្លាយជាកម្មករក្រៅប្រព័ន្ធ ដែលជាក្រុមមួយមិនទទួលបានការការពារ និងខ្វះរបបសន្តិសុខសង្គម។ NESDC បានបង្ហាញថា អត្រាភាពគ្មានការងារធ្វើបានឈានដល់កម្រិតខ្ពស់ ក្នុងត្រីមាសទី១នៃឆ្នាំនេះ ដោយសាររលកនៃការផ្ទុះឡើងនៃជំងឺកូវីដ-១៩ ក្នុងនោះអត្រាភាពគ្មានការងារធ្វើមានចំនួន ១,៩៦% នៅក្នុងត្រីមាសទី ១ ឆ្នាំ២០២១ ដែលតំណាងឱ្យកម្មករគ្មានការងារធ្វើចំនួន ៧៥,៨ ម៉ឺននាក់ កើនឡើងពី ១,៨៦%នៃត្រីមាសទី ៤ ឆ្នាំ២០២០។ ដោយឡែកចំនួនម៉ោងធ្វើការសរុបក៏បានធ្លាក់ចុះផងដែរគឺ ៤០,១ ម៉ោងក្នុងមួយសប្តាហ៍នៅក្នុងត្រីមាសទី១ ដែលថយចុះ ១,៨% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន និងធ្លាក់ចុះ ៦ ត្រីមាស ជាប់ៗគ្នា។ ចំនួនប្រជាជនដែលស្ថិតក្នុងកម្លាំងពលកម្មមានចំនួន ៣៨,៨លាននាក់ក្នុងត្រីមាសទី១ ឆ្នាំ២០២១ កើនឡើង ១,៥% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ដោយសារការចូលធ្វើការរបស់ប្រជាជនដែលពីមុនមិនមែនជាកម្លាំងពលកម្ម។ ដូច្នេះ ចំនួនកម្មករដែលមានការងារធ្វើសរុបបានឈានដល់ ៣៧,៦ លាននាក់ កើនឡើង ០,៤% ដោយសារការកើនឡើងនូវការងារក្នុងវិស័យកសិកម្ម ដែលបានស្រូបយកកម្មករមួយចំនួនដែលបានបោះបង់ការងារក្នុងវិស័យផ្សេងៗ។ ការណ៍នេះបានធ្វើឱ្យតម្លៃផលិតផលកសិកម្មជាច្រើន បានកើនឡើងគួរឱ្យកត់សម្គាល់ និងបានទាក់ទាញកម្មករកាន់តែច្រើនចូលមកក្នុងវិស័យនេះ។

របាយការណ៍របស់ NESDC ក៏បានបង្ហាញដែរថា បំណុលគ្រួសារ មានចំនួន ១៤,០២ទ្រីលានបាតក្នុងត្រីមាសទី៤ឆ្នាំ ២០២០ កើនឡើង៣,៩%បើប្រៀបធៀបទៅនឹង៤%នៅក្នុងត្រីមាសមុន និងមានចំនួន៨៩,៣% នៃផ.ស.ស។ បំណុលគ្រួសារនៅតែបន្តកើនឡើងខ្ពស់នៅឆ្នាំ២០២១ ដោយសារការធ្លាក់ចុះនៃសេដ្ឋកិច្ច។ សេដ្ឋកិច្ចមិនទាន់ងើបឡើងដល់កម្រិតមុនផ្ទុះជំងឺកូវីដ-១៩ទេ ហើយទីផ្សារការងារអាចនឹងរងផលប៉ះពាល់កាន់តែខ្លាំង ដែលបានជះឥទ្ធិពលដល់ប្រាក់ចំណូល និងធ្វើឱ្យគ្រួសារមានបញ្ហាសាច់ប្រាក់កាន់តែច្រើន។

គ្រួសារដែលមានប្រាក់ចំណូលទាប នឹងត្រូវប្រយ័ត្នចំពោះការចំណាយរបស់ពួកគេនៅឆ្នាំ ២០២១ ជាពិសេសសម្រាប់ទំនិញប្រើប្រាស់បានយូរ។ ជាលទ្ធផល តម្រូវការក្នុងវិស័យអចលនទ្រព្យ និងរថយន្តមានការថយចុះគួរឱ្យកត់សម្គាល់។ ទន្ទឹមនឹងនេះ តម្រូវការប័ណ្ណឥណទាន និងប្រាក់កម្ចីប្រើប្រាស់ផ្ទាល់ខ្លួន អាចនឹងមានការកើនឡើងដោយសារតែបញ្ហាសាច់ប្រាក់ងាយស្រួល ក៏ដូចជាប្រាក់កម្ចីមានការប្រាក់ទាបសម្រាប់ពលរដ្ឋ ដែលផ្ដល់ដោយស្ថាប័នហិរញ្ញវត្ថុ ដែលគ្រប់គ្រងដោយរដ្ឋាភិបាល ដូចជា ធនាគារប្រាក់សន្សំរបស់រដ្ឋាភិបាលជាដើម។
*ដោយ សេន ចន្ទី*

*ប្រភព៖ bangkokpost. ចេញផ្សាយថ្ងៃទី២៥ខែឧសភា ឆ្នាំ២០២១*

## ថវិកាចរន្តនៃប្រទេសសិង្ហបុរីសម្រាប់ឆ្នាំ២០២១

ប្រាក់ចំណូលប្រតិបត្តិការរបស់ប្រទេសសិង្ហបុរី មានការកើនឡើងជារៀងរាល់ឆ្នាំ ហើយចំណាយប្រតិបត្តិការក៏កើនដូចគ្នា។ ប្រាក់ចំណូលប្រតិបត្តិការត្រូវបានប៉ាន់ប្រមាណថានឹងមានចំនួន ៧៦ ៦៣៦ លានដុល្លារ នៅក្នុងឆ្នាំ២០២១។ កំណើននេះ ភាគច្រើនបានមកពីពន្ធលើប្រាក់ចំណេញក្រុមហ៊ុនសាជីវកម្ម (Corporate Income Tax) ពន្ធផ្សេងទៀត ពន្ធលើទ្រព្យសម្បត្តិ និងពន្ធលើទំនិញនិងសេវាកម្ម។

ការប្រមូលចំណូលសម្រាប់ឆ្នាំសារពើពន្ធ២០២០ មានចំនួន ៦៤ ៦០៨លានដុល្លារ ទាបជាងផែនការប្រមាណជា ១១ ៤០២ លានដុល្លារ ឬ ស្មើនឹង១៥% ដោយសារតែការពន្យារពេលការបង់ពន្ធ ការលើកលែងការបង់ពន្ធ និងការបង្វិលប្រាក់ត្រឡប់ទៅវិញសម្រាប់ពន្ធលើប្រាក់ចំណេញក្រុមហ៊ុនសាជីវកម្ម ពន្ធផ្សេងៗ និងពន្ធលើទ្រព្យសម្បត្តិនានា ក្នុងគោលបំណងគាំទ្រដល់សេដ្ឋកិច្ច ដែលកំពុងរងផលប៉ះពាល់ពីជំងឺកូវីដ-១៩។

ការចំណាយសរុប ត្រូវបានគេប៉ាន់ប្រមាណថានឹងមានចំនួន ១០២ ៣៣៨ លានដុល្លារក្នុងឆ្នាំ២០២១ ដែលកើនឡើងធៀបនឹងឆ្នាំ២០២០ មានតែ ៩៤ ០៥៦ លានដុល្លា។ សម្រាប់ឆ្នាំ២០២១ ចំណាយប្រតិបត្តិការត្រូវបានប៉ាន់ប្រមាណថា មានចំនួន ៨២ ៤៦៥លានដុល្លារ ខ្ពស់ជាងឆ្នាំមុនចំនួន ៤ ៨២១ លានដុល្លារ។ ចំណែកឯការចំណាយលើការអភិវឌ្ឍ ត្រូវបានប៉ាន់ប្រមាណថាមានចំនួន ១៩ ៨៧៣លានដុល្លារនៅក្នុងឆ្នាំ២០២១ ដែលកើនពី ១៦ ៤១២លានដុល្លារក្នុងឆ្នាំ២០២០។
*ដោយ ធីម ប៊ុនធឿន*

| គិតជា លានដុល្លារ | 2018 | 2019 | 2020 (កែតម្រូវ) | 2021 (ថវិកា) |
|---|---|---|---|---|
| ចំណូលប្រតិបត្តិការ | 73,738 | 74,274 | 64,608 | 76,636 |
| សរុបចំណាយ | 77,824 | 75,337 | 94,056 | 102,338 |
| អតិរេក / ឱនភាពបឋម | (4,086) | (1,063) | (29,448) | (25,702) |

*ប្រភព ៖* mof.gov.sg

# សេដ្ឋកិច្ចសកល

## ទីផ្សារអចលនទ្រព្យពិភពលោក ត្រៀមនឹងកើនឡើងនៅឆ្នាំនេះ




*ប្រភព៖ Reuters ២០២១, រូបភាពក្រាហ្វិច៖ Richa Rebello និង Tushar Goenka /Reuters Graphics*

យោងតាមលទ្ធផលនៃការស្ទង់មតិរបស់ Reuters ជាមួយអ្នកជំនាញទីផ្សារអចលនទ្រព្យជាង ១០០នាក់ ដែលបានធ្វើឡើងកាលពីថ្ងៃទី១១-២៤ ខែឧសភា ឆ្នាំ២០២១ បានបង្ហាញថា តម្លៃផ្ទះ ត្រូវបានព្យាករណ៍ថានឹងកើនឡើងខ្ពស់នៅឆ្នាំនេះ នៅក្នុងប្រទេសមួយចំនួនដូចជា៖ សហរដ្ឋអាមេរិក អង់គ្លេស កាណាដា អូស្ត្រាលី និង នៅទីក្រុងឌូបៃ បើធៀបនឹងរយៈពេល ៣ខែមុនប៉ុណ្ណោះ។ និន្នាការនៃការកើនឡើងនេះ គឺដោយសារការរំពឹងទុកនូវការបន្តផ្ដល់កម្ចីជាមួយនឹងអត្រាការប្រាក់ទាប អត្រានៃការចាក់វ៉ាក់សាំងឆាប់រហ័ស និងការបន្ធូរបន្ថយវិធានការរឹតត្បិតនានា ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ យ៉ាងខ្លាំងកាលពីឆ្នាំមុន ក៏ដូចជា ការកើនឡើងនូវផ.ស.ស. និងអតិផរណាតម្លៃទំនិញជាងការរំពឹងទុក ព្រមទាំងការគាំទ្រផ្នែករូបិយវត្ថុ និងសារពើពន្ធរបស់រដ្ឋាភិបាល និងការងើបឡើងវិញនៃសេដ្ឋកិច្ចបន្ទាប់ពីជំងឺរាតត្បាតកូវីដ-១៩។

ជាក់ស្ដែង តម្លៃផ្ទះនៅប្រទេសអូស្ត្រាលី និងកាណាដាត្រូវបានព្យាករណ៍ថានឹងកើនឡើងចំនួនពីរខ្ទង់នៅឆ្នាំនេះ ខណៈនៅទីក្រុងឌូបៃ ត្រូវបានរំពឹងថានឹងកើនឡើងជាលើកដំបូងក្នុងរយៈពេល ៦ឆ្នាំនេះ។

ចំណែកឯ តម្លៃផ្ទះនៅចក្រភពអង់គ្លេស ត្រូវបានព្យាករណ៍ថានឹងកើនឡើងខ្លាំង ដោយសារការបន្តដាក់ចេញនូវគោលនយោបាយគាំទ្ររបស់រដ្ឋាភិបាល ស្របពេលជាមួយនឹងការកើនឡើងនូវតម្រូវការសម្រាប់កន្លែងរស់នៅកាន់តែច្រើន។

ដូចគ្នាដែរ នៅសហរដ្ឋអាមេរិក តម្លៃផ្ទះត្រូវបានព្យាករណ៍ថានឹងកើនឡើងទ្វេដងនៃអត្រាដែលបានព្យាករណ៍ទុកនៅក្នុងខែកុម្ភៈ ឆ្នាំនេះ ដោយសារការផ្គត់ផ្គង់ទាប និងការគាំទ្រនៃចំណាយដ៏ច្រើនសន្ធឹកសន្ធាប់ ព្រមទាំងការកំណត់អត្រាការប្រាក់ជិតសូន្យភាគរយរបស់រដ្ឋាភិបាល។

ដោយឡែក ទស្សនវិស័យសម្រាប់ទីផ្សារលំនៅឋាននៅប្រទេសឥណ្ឌា គឺជាករណីលើកលែងមួយដែលគួរឱ្យកត់សម្គាល់ចំពោះនិន្នាការពិភពលោក។ តម្លៃផ្ទះនៅ

ប្រទេសឥណ្ឌា ត្រូវបានព្យាករណ៍ថានឹងនៅទ្រឹងនៅឆ្នាំនេះ ដោយសាររងផលប៉ះពាល់ពីការរាតត្បាតរលកទីពីរនៃជំងឺកូវីដ-១៩ ដែលបានធ្វើប៉ះពាល់ដល់តម្រូវការផ្ទះ និងការទូទាត់បង្វិលសងពន្ធ និងការលើកទឹកចិត្តរបស់រដ្ឋាភិបាលដល់អ្នកអភិវឌ្ឍន៍អចលនទ្រព្យ៕

*ដោយ ស៊ិន សុភារ៉ា*

*ប្រភព៖ គេហទំព័រសារព័ត៌មាន Reuters ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១*

## ការកើនឡើងខ្ពស់នៃកម្រិតបំណុលនៅប្រទេសសេដ្ឋកិច្ចកំពុងរីកចម្រើន អាចនឹងធ្វើឱ្យការស្តារឡើងវិញនៃសេដ្ឋកិច្ចពីវិបត្តិជំងឺកូវីដ-១៩ មានភាពយឺតយ៉ាវ និងពង្រីកគម្លាតជាមួយប្រទេសសេដ្ឋកិច្ចអភិវឌ្ឍន៍




*ប្រភព៖ CNBC ២០២១*

យោងតាមប្រសាសន៍របស់លោក Steve Cochrane ប្រធានសេដ្ឋវិទូប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិកនៃក្រុមហ៊ុន Moody's Analytics បំណុលពិភពលោក បានកើនឡើងដល់ ២៤ទ្រីលានដុល្លារអាមេរិក នៅក្នុងឆ្នាំ២០២០។ កំណើននេះ បានធ្វើឱ្យបំណុលពិភពលោក កើនឡើងក្នុងកំណត់ត្រាខ្ពស់ថ្មី ស្មើនឹង ៣៦៦% នៃផ.ស.ស. ពិភពលោក។ ក្នុងនោះដែរ បំណុលសរុបនៅក្នុងប្រទេសសេដ្ឋកិច្ចកំពុងរីកចម្រើន (Emerging markets) បានកើនឡើងទ្វេដង ក្នុងរយៈពេល ១ទសវត្សរ៍ចុងក្រោយ ហើយបច្ចុប្បន្ននេះ បំណុលសរុបមានចំនួនមួយភាគបីនៃបំណុលដែលមិនទាន់ទូទាត់នៃបំណុលពិភពលោក។

លោក Cochrane បានមានប្រសាសន៍ទៀតថា ការកើនឡើងខ្ពស់នៃកម្រិតបំណុលអាចបណ្តាលឱ្យប្រទេសសេដ្ឋកិច្ចកំពុងរីកចម្រើន ស្ថិតនៅពីក្រោយប្រទេសសេដ្ឋកិច្ចអភិវឌ្ឍន៍ (Developed markets) ក្នុងការស្តារសេដ្ឋកិច្ចឡើងវិញពីការរាតត្បាតនៃជំងឺកូវីដ-១៩។

លោក Cochrane ក៏បានកត់សម្គាល់ផងដែរថា ប្រទេសសេដ្ឋកិច្ចកំពុងរីកចម្រើន ជាទូទៅមានភាពយឺតយ៉ាវក្នុងការធានានូវសុវត្ថិភាព និងការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ បើធៀបទៅនឹងប្រទេសសេដ្ឋកិច្ចអភិវឌ្ឍន៍។ ទន្ទឹមនឹងនេះ ការកើនឡើងនៃបន្ទុកបំណុល អាចនឹងនាំឱ្យរដ្ឋាភិបាលនៃប្រទេសសេដ្ឋកិច្ចអភិវឌ្ឍន៍ទាំងនោះ កាត់បន្ថយចំណាយជាងមុន ដើម្បីទុកដោះស្រាយបំណុល។

ទោះយ៉ាងនេះក្តី លោក Cochrane បានបញ្ជាក់ថា ផលប៉ះពាល់ពិតប្រាកដនោះគឺជាភាពខុសគ្នានៃការស្តារឡើងវិញនៃសេដ្ឋកិច្ចរវាងប្រទេសសេដ្ឋកិច្ចអភិវឌ្ឍន៍ និងប្រទេសសេដ្ឋកិច្ចកំពុងរីកចម្រើន ដោយសារបន្ទុកបំណុលបានកើនភាគច្រើននៅក្នុងប្រទេសសេដ្ឋកិច្ចកំពុងរីកចម្រើន។

បន្ថែមពីនេះ ពួកគេអាចនឹងមានការលំបាកខ្លាំងទាក់ទងនឹងការដោះស្រាយបំណុលនាពេលខាងមុខ។

ជារួម លោក Cochrane បានបញ្ជាក់ថា កំណើនសេដ្ឋកិច្ចនឹងមិនស្មើគ្នាទេនៅជុំវិញពិភពលោក។ លោករំពឹងថា កំណើនសេដ្ឋកិច្ចនៅសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប ទំនងជានឹងកើនឡើងនៅរដូវក្តៅនេះ ខណៈប្រទេសសេដ្ឋកិច្ចកំពុងរីកចម្រើន ប្រហែលជាត្រូវរង់ចាំយូរបន្តិច៕ *ដោយ ស៊ិន សុភាព៉*

*ប្រភព៖ គេហទំព័រសារព័ត៌មាន CNBC ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ ២០២១*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះ រួមមាន ៖ អត្រាអតិផរណាប្រចាំឆ្នាំនៅក្នុងប្រទេសអ៊ីតាលី រយៈពេល ០៤ខែ ដើមឆ្នាំ២០២១, អត្រាកំណើនផលិតកម្មកម្មន្តសាលនៅប្រទេសកូរ៉េខាងត្បូង ក្នុងដើមត្រីមាស ឆ្នាំ ២០២១,អតិរេកពាណិជ្ជកម្មរបស់ប្រទេសកូរ៉េខាងត្បូង គិតត្រឹមខែមេសា ឆ្នាំ២០២១ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន, អត្រានិកម្មភាពនៅប្រទេសអាឡឺម៉ង់ ក្នុងដើមត្រីមាសឆ្នាំ ២០២១, អតិរេកពាណិជ្ជកម្មរបស់ប្រេស៊ីល ក្នុងខែមេសាឆ្នាំ ២០២១, អត្រាអតិផរណាប្រចាំឆ្នាំរបស់ឥណ្ឌូនេស៊ី ក្នុងខែមេសាឆ្នាំ ២០២១, កំណើនប្រាក់ចំណូលពន្ធរបស់ប្រទេសអាហ្សង់ទីននៅក្នុងខែមេសា ធៀបនឹងខែមីនា ឆ្នាំ២០២១, តម្រូវការបរទេសលើផលិតផលអូស្ត្រាលីបានធ្លាក់ចុះ ចាប់ពីខែមីនាឆ្នាំ ២០២១ ដោយសារតែការរីករាលដាលនៃការឆ្លងមេរោគ Covid-១៩, ការលក់រាយនៅបារាំងបានថយចុះនៅខែមីនាឆ្នាំ ២០២១ ធៀបនឹងខែមុន និង កំណើនអត្រានិកម្មភាពរបស់ប្រទេសកាណាដានៅក្នុងខែមេសាឆ្នាំ ២០២១ លើសពីការរំពឹងទុក។

<u>ថ្ងៃចន្ទ ទី៣១ ខែឧសភា ឆ្នាំ២០២១</u>

- អត្រាអតិផរណាប្រចាំឆ្នាំនៅក្នុងប្រទេសអ៊ីតាលី រយៈពេល០៤ខែ ដើមឆ្នាំ២០២១
- អត្រាកំណើនផលិតកម្មកម្មន្តសាលនៅប្រទេសកូរ៉េខាងត្បូង ក្នុងដើមត្រីមាសឆ្នាំ២០២១។

<u>ថ្ងៃអង្គារ៍ ទី០១ ខែមិថុនា ឆ្នាំ២០២១</u>

- អតិរេកពាណិជ្ជកម្មរបស់ប្រទេសកូរ៉េខាងត្បូង គិតត្រឹមខែមេសា ឆ្នាំ២០២១ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន
- អត្រានិកម្មភាពនៅប្រទេសអាឡឺម៉ង់ ក្នុងដើមត្រីមាសឆ្នាំ ២០២១។

<u>ថ្ងៃពុធ ទី០២ ខែមិថុនា ឆ្នាំ២០២១</u>

- អតិរេកពាណិជ្ជកម្មរបស់ប្រេស៊ីល ក្នុងខែមេសា ឆ្នាំ ២០២១
- អត្រាអតិផរណាប្រចាំឆ្នាំរបស់ឥណ្ឌូនេស៊ី ក្នុងខែមេសាឆ្នាំ ២០២១។

<u>ថ្ងៃព្រហស្បត៍ ទី០៣ ខែមិថុនា ឆ្នាំ២០២១</u>

- កំណើនប្រាក់ចំណូលពន្ធនៃប្រទេសអាហ្សង់ទីននៅក្នុងខែមេសា ធៀបនឹងខែមីនា ឆ្នាំ២០២១
- តម្រូវការបរទេសលើផលិតផលអូស្ត្រាលី បានធ្លាក់ចុះ ចាប់ពីខែ មីនាឆ្នាំ ២០២១ ដោយសារតែការរីករាលដាលនៃCovid-១៩។

ថ្ងៃសុក្រ ទី០៤ ខែមិថុនា ឆ្នាំ២០២១

- ការលក់រាយនៅបារាំងបានថយចុះនៅខែមីនា ឆ្នាំ ២០២១ ធៀបនឹងខែមុន
- កំណើនអត្រានីកម្មភាពរបស់ប្រទេសកាណាដា នៅខែមេសាឆ្នាំ ២០២១ លើសពីការរំពឹងទុក។